**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៧៤ ........ **អយក.** សស

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារពិនិត្យ តាមដាន និងវាយតម្លៃ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

* * * * *

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- ប្រកាសលេខ១៤៣៥ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងាររៀបចំគោលនយោបាយអធិការកិច្ច ដើម្បីពិនិត្យ តាមដាន វាយតម្លៃ និងកែលម្អគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ។

**ប្រការ ២.-**

ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- ឯ.ឧ.បណ្ឌិត | ហង់ជួន | ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២- ឯកឧត្តម | យក់ | ង៉ុយ | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣- ឯកឧត្តម | ឡៅ | ឈីវអ៊ាវ | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤- ឯកឧត្តម | ទូច | វិសាលសុខ | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥- ឯកឧត្តម | ថោង | បូរ៉ាន់ | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម | ម៉ក់ | ងយ | អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៧- ឯកឧត្តម | សាន | មន្ទិយ៉ា | អគ្គលេខាធិការនៃគ.ទ.ក | សមាជិក |
| ៨- លោក | និត | ប៊ុនឡៃ | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៩- លោក | វ័ត្ន | ឆាង | ប្រធាននាយកដ្ឋានក្រោយឧត្តមនៃគ.ទ.ក | សមាជិក |
| ១០-លោក | គង់ | ភូមីកា | ប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១១-លោក | ច័ន្ទ | វ័ត្ន | ប្រធាននា.ស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១២-លោក | ស៊ិន | សេងហុក | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១៣-លោក | យូ | វីរៈ | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១៤-លោក | អ៊ុន | លាង | អនុប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ១៥-ល.ស | លឹម | ដ៉ោ | អនុប្រធាននា.ស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៦-ល.ស | សាម | សុភក្ត្រ័ទ្រី | ប្រធានការិ.គោលនយោបាយ និងកម្មវិធីសិក្សា | សមាជិក |
| ១៧-លោក | ប៉េង | យ៉ីទី | ប្រធានការិ.អធិការកិច្ច | សមាជិក |
| ១៨-ល.ស | រស់ | ចាន់សោភា | អនុប្រធានការិ.គោលនយោបាយ និងកម្មវិធីសិក្សា | សមាជិក |
| ១៩-លោក | សុង | សុខសាន្ត | អនុប្រធានការិ.ចុះឈ្មោះចូលរៀន | សមាជិក |
| ២០-ល.ស | ងួន | កល្យាណ | អនុប្រធានការិ.ចុះឈ្មោះចូលរៀន | សមាជិក |
| ២១-លោក | អោ | ប៊ុនស្រ៊ុន | អនុប្រធានការិ.អធិការកិច្ច | សមាជិក |
| ២២- លោក | សៅ | ធូ | អនុប្រធានការិ.អធិការកិច្ច | សមាជិក |
| ២៣-ល.ស | សៀ | នីយ៉ា | មន្ត្រីនាយកដ្ឋានឧត្តមសិក្សា | លេខាសម្របសម្រួលការងារ |
| ២៤-កញ្ញា | ហ៊ាន | និមល | មន្ត្រីនាយកដ្ឋានឧត្តមសិក្សា | លេខាសម្របសម្រួលការងារ |

សមាសភាពក្រុមការងារនេះ អាចធ្វើការកែសម្រួល និងស្នើសុំបន្ថែមក្នុងករណីចាំបាច់។

**ប្រការ ៣.-**

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំក្របខ័ណ្ឌគោលនយោបាយអធិការកិច្ច ដើម្បីពិនិត្យតាមដាន វាយតម្លៃ និងកែលម្អគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ។
- រៀបចំបទដ្ឋាន និងឧបករណ៍អធិការកិច្ច សម្រាប់ពិនិត្យ តាមដាន និងវាយតម្លៃ
- រៀបចំផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តការងារនេះ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារជូនឯកឧត្តមរដ្ឋមន្ត្រី។

**ប្រការ ៤.-**

ក្រុមការងារនេះ ត្រូវមានថវិការបស់ខ្លួន ដែលជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបំពេញការងារស្របតាមតម្រូវការចាំបាច់នានា។

**ប្រការ ៥.-**

ប្រធានក្រុមការងារនេះ មានសិទ្ធិដូចខាងក្រោម៖

- កោះអញ្ជើញអនុប្រធាន និងសមាជិកចូលរួមតាមការចាំបាច់
- អាចចាត់តាំងជាផ្នែកៗ តាមការចាំបាច់
- អាចអញ្ជើញមន្ត្រី ដែលមានបទពិសោធការងារឧត្តមសិក្សាតាមការចាំបាច់។

**ប្រការ ៦.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គលេខាធិការនៃគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្ម ប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៥ ឆ្នាំ២០១៥

បណ្ឌិត ហង់ ជួន ណារ៉ុន

*ចម្លងជូន ៖*

*-អគ.របហ -អគ.ឧស*

*-គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា*

*-គ្រប់អង្គភាព និងគ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្រសួង ដែលពាក់ព័ន្ធ*

*-សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា «ដើម្បីជូនជ្រាបជាព័ត៌មាន»*

*-ដូចក្នុងប្រការ៥ « ដើម្បីអនុវត្ត »*

*-កាលប្បវត្តិ*

*-ឯកសារនា.ឧស*